
រឿង
កុប និង កុល

# រឿង តុប និង តុល

និពន្ធដោយ អ្នកស្រី យឹម នីម៉ូល្លា
គូររូបដោយ លោក គាំ សារ៉ែន

រក្សាសិទ្ធិដោយ អង្គការសន្តិស្នេហ៍គ្រុចិត្ត(SVA)

បោះពុម្ពឆ្នាំ១៩៩៨

# រឿង តុប និង តុល



គូរដោយ គាំ សារ៉ែន

បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)



តុលជាកូនមីងសំ ។ ថ្ងៃមួយ នាងតាមម្ដាយទៅស្រុកកំណើតដើម្បីសួរសុខទុក្ខគ្រួសារម្ដាយមីងនាង ។ នៅទីនោះ នាងមានប្អូនជីដូនមួយម្នាក់ ឈ្មោះ តុប ដែលត្រូវជាកូនម្ដាយមីងនាង ។ នាងតុបអាយុ ១០ ឆ្នាំ ស្រករគ្នានឹងនាងតុលដែរ ។ នៅពេលចុះពីរថយន្តឈ្នួល តុល និងតុបបានរត់រកគ្នាដោយក្ដីរីករាយ ។ ចាស់ៗជួបគ្នាញញឹមរាក់ទាក់រកគ្នា សួរសុខទុក្ខគ្នាទៅវិញទៅមក ។





មីងសំលាន់មាត់ថា "សុខឯង និងកូនម៉េចក៏ស្គម ហើយស្លេកម្ល៉េះ?" ។ មីងសុខមុខស្លុត ហើយឆ្លើយតប ទៅបង ÷

ចាស! ខ្ញុំ និងកូនពុំដឹងជាយ៉ាងម៉េចទេ ចេះតែក្តៅ ខ្លួន ជួនកាលរាកផង ។

មីងសំងាកមើលមកកូន រួចស្រែកហៅ ÷

អីតុល មកនេះសិន!

កុមារីតុលហាក់ដឹងខ្លួន ស្ទុះមករកម្តាយមីង ដោយ លើកដៃជំរាបសួរយ៉ាងទន់ភ្លន់ :

អ្នកមីង ខ្ញុំជំរាបសួរ!

មីងសុខលើកដៃបបោសអង្អែលក្បាលក្មួយ ដោយក្តី ស្រឡាញ់ពេញចិត្ត រួចលាន់មាត់ថា ÷

ក្មួយមីងចេះណាស់ ហើយធំសន្ទឹកតែម្តង ! ។



តុបឃើញតុលសំពះម្ដាយខ្លួនដូច្នោះ ក៏ងាកមកមើលមុខម្ដាយ ។ មីងសុខក៏ពោលទៅកាន់តុបភ្លាម ៖

ម៉េចឯងមិនធ្វើដូចតុល ។

តុបធ្វើអេះអុញព្រោះពុំធ្លាប់សំពះ ។ មួយសន្ទុះមកទើបតុបលើកដៃគោរពម្ដាយធំទាំងឆ្គង ៖

ជំរាបសួរអ៊ំ! ម្ដាយតុបគ្រវីក្បាលដោយហួសចិត្ត រីឯម្ដាយតុលញញឹម ហើយពោលថា៖ កុំបន្ទោសក្មេង គឺព្រោះតែឯងមិនទម្លាប់កូនហ្នឹងណា៎! ។





ចាស់ៗបណ្ដើរគ្នាចូលក្នុងផ្ទះ  សំណេះសំណាលគ្នា
យ៉ាងរីករាយ ។ តុប និងតុលក៏បបួលគ្នាទៅលេងក្រោយ
ផ្ទះ ។  អ្នកទាំងពីរប្រដេញគ្នាលេងយ៉ាងសប្បាយក្បែរ
ត្រពាំងមួយ ។ ពេលហត់ខ្លាំង គេនាំគ្នាឈប់ ។







តុលស្រេកទឹកខ្លាំងណាស់ នាងបំរុងសួរតុប ក៏ប៉ុន្តែ តុបបានដើរទៅដល់មាត់ត្រពាំងទៅហើយ ។ តុលដើរតាមក្រោយ ឃើញតុបអោនក្បង់ទឹកផឹកធ្វើព្រងើយ ។ ផឹកឆ្អែតហើយ តុបបបួលតុលថា ÷

មក ! ឯងផឹកទឹកទេ ? ។





តុលមិនឆ្លើយ តែភ្នែកនាងខំប្រឹងសម្លឹងមើលទឹកត្រពាំងដែលមានខ្យងតូច ធំ កំពុងហាមាត់ ។ នាងឃើញសារាយអណ្ដែត ឫសកំពឹងពួយខ្មៅរវាមដែលមានដង្កូវបាក់ខ្នងមួយកំពុងវារតើមៗពីលើ និងឃើញកូនសត្វល្អិតដទៃទៀតហែលចុះឡើង ។ នាងមិនដាច់ចិត្តផឹកទឹកត្រពាំងនេះទាល់តែសោះ ។ នាងតុបឃើញដូច្នេះ ទឹកឆ្ងល់ ក៏សួរភ្លាម :

ហេតុអ្វីឯងមិនផឹកទឹកនេះ? ក្មេងក្នុងភូមិយើងដែលមកឃ្វាលគោ តែងក្បង់ទឹកនេះផឹកជារឿយៗ ។

តុលធ្វើមុខជូរ គ្រវីក្បាល ហើយឆ្លើយតបៈ

ខ្ញុំមិនហ៊ានផឹកទឹកនេះទេ! ។





តុលរត់ទៅផ្ទះ ហើយរត់ត្រឡប់មកវិញ ដោយកាន់ដបទឹកមួយមកផង ។ តុបឆ្ងល់សួរថា÷

ទឹកស្អីនឹង? ឆ្ងាញ់ទេ?

តុលឆ្លើយៈ

ទឹកឆ្អិនណា៎! ម៉ែខ្ញុំបានច្រកវាទុកក្នុងដបសម្រាប់ផឹក នៅពេលធ្វើដំណើរមកតាមផ្លូវ ។

តុបសើច ហើយពោលថាៈ

គ្រាន់តែទឹកផឹកសោះ ចាំបាច់ច្រកយកមកដែរ ! ។

តុលឆ្លើយដោយញញឹមៈ

ម៉ែខ្ញុំតែងតែដាំទឹកអោយពុះ ទុកសម្រាប់ញ៉ាំនៅផ្ទះជានិច្ច ឯងដឹងទេ? ។



តុបលែងសួរ ក៏បបួលតុលទៅរើសក្តិបស្វាយក្បែរផ្ទះ ។ ស្វាយជ្រុះក្រាលលើដី តុបរើសយកស្វាយមួយមកជូតនឹងអាវខ្វាច់ ហើយដាក់ក្នុងមាត់ ខាំក្រឹប ។ តុលរើសស្វាយបានមួយទូកដៃ តែនាងមិនញាំភ្លាមទេ ។ នាងទុកយកទៅលាងឯផ្ទះ ។ បន្ទាប់ពីញាំស្វាយអស់ពីរបីតុបក្អួរពោះគ្រូកៗ ។ តុបទម្លាក់ស្វាយចោលលើដី រួចរត់រឹងទៅក្បែរភ្លឺស្រែ អង្គុយចុះ ហើយស្រែកប្រាប់តុលថា :

គ្នាបត់ជើងសិន ។

តុលស្រែកសួរតុបវិញ :

ម្តេចឯងមិនទៅបត់ជើងក្នុងបង្គន់ ។

តុបឆ្លើយវិញ :

ផ្ទះខ្ញុំគ្មានបង្គន់ទេ ពេលណាខ្ញុំឈឺពោះ ម៉ែខ្ញុំតែងដេញអោយមកទីនេះ ឬទៅព្រៃក្រោយផ្ទះ ។


ការពារ ប្រសើរជាងព្យាបាល

បន្ទាប់មក លោកគ្រូពេទ្យបានផ្តល់ដំបូន្មានថា មេរោគមាននៅក្នុងអាហារ ឬទឹកពុំស្អាត ។ ការខ្វះអនាម័យអាចនាំអោយខូចសុខភាព ឧស្សាហ៍ចុះរាក និងអាចបណ្តាលអោយកើតជម្ងឺអាសន្នរោគស្លាប់ភ្លាមក៏មាន ។ មិនតែប៉ុណ្ណោះ វាអាចអោយយើងកើតព្រូន អៀន ឬតេនញ៉ាជាដើម ដែលចាំបំផ្លាញសុខភាពយើងមួយថ្ងៃបន្តិចៗ រហូតដល់ធ្វើអោយយើងស្លាប់បាន ។





តុបស្តាប់ឮម្តាយ និងគ្រូពេទ្យនិយាយអំពីមេរោគទាំងនោះ ធ្វើអោយនាងនឹកស្រម៉ៃឃើញ កាលនាងក្បង់ទឹកឆៅផឹកយ៉ាងឆ្ងាញ់ ខាំក្តិបស្វាយប្រឡាក់ដី ឃើញដង្កូវក្នុងត្រពាំង ហើយស្រម៉ៃរហូតដល់ឃើញព្រូនមួយយ៉ាងធំ កំពុងខាំជញ្ជក់ពោះវៀននាង ។ តុបគ្រវៀងខ្លួនដោយខ្លាច ហើយនឹកក្នុងចិត្តថា នាងនឹងមិនប្រព្រឹត្តដូចមុនទៀយ ៕

ចប់



